អន្តរបៀរ៍

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ តុលាការខ្មែរប្រកបដោយអគតិធម៌ កាត់សេចក្តីពុំមានយុត្តិធម៌ឡើយ ។

www.hoksavann.org

ថ្ងៃទី២២ ធ្នូ ២០១២



អគតិធម៌ប្រែថា ធម៌លំអៀងមាន៤យ៉ាងគឺ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ទោសាគតិ លំអៀងព្រោះស្អប់, ភយាគតិ លំអៀងព្រោះខ្លាច, មោហាគតិ លំអៀងព្រោះល្ងង់ ។ អគតិធម៌ទាំងបួននេះ ជាអំពើអយុត្តិធម៌ ប្រែថា ធម៌ពុំត្រឹមត្រូវ ជាគន្លងនៃអំពើបាប ។

ពាក្យថា ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់ សំរេចសេចក្តីអ្វីមួយ ដោយការកាន់ជើង បើចៅក្រមកាត់សេចក្តីសំរេចឲ្យអ្នកដែលខ្លួនកាន់ជើងនោះឈ្នះ ព្រោះហេតុតែសេចក្តីស្រឡាញ់ ទោះអ្នកនោះមានកំហុសក៏ដោយ ។

ទោសាគតិ លំអៀងព្រោះស្អប់ បើទោះបីអ្នកដែលខ្លួនស្អប់នោះធ្វើត្រូវក៏ដោយ ក៏ឲ្យខុស ឲ្យចាញ់ដែរ ព្រោះហេតុស្អប់ ។

ភយាគតិ លំអៀងព្រោះភ័យខ្លាច ពុំហ៊ានសំរេចឲ្យខុសដល់អ្នកដែលមានកំហុស ដែលជាអ្នកមានអំណាចបុណ្យស័ក្តិ មានទ្រព្យសម្បត្តិច្រើន ដោយខ្លាចអ្នកនោះធ្វើសេចក្តីអន្តរាយសងសឹកដល់ខ្លួនវិញ នេះលំអៀងព្រោះភ័យខ្លាច ។

មោហាគតិ លំអៀងព្រោះល្ងង់ ឬពុំដឹងការពិត គឺអ្នកមានវិជ្ជា មានបញ្ញាទន់ខ្សោយ ឬជាអ្នកគ្មានសមត្ថភាពបានសំរេចបញ្ហាអ្វីមួយពុំត្រឹមត្រូវ គឺសំរេចសេចក្តីទៅតាមភាពល្ងង់ខ្លៅរបស់ខ្លួន ។

អគតិធម៌ទាំងបួននេះ ជាធម៌អកុសល ជាអំពើបាប ដែលលោកអ្នកសប្បុរសតែងវៀរចាក ជាពិសេសចៅក្រមកាត់សេចក្តីក្នុងតុលាការ ត្រូវតែវៀរចាកកុំប្រព្រឹត្តធ្វើ ទើបការកាត់សេចក្តីមានយុត្តិធម៌ ។

ចំពោះតុលាការក្នុងប្រទេសដែលកាន់របបប្រជាធិបតេយ្យ មានអំណាចឯករាជ្យដាច់ចេញពីអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ គឺរដ្ឋាភិបាល ។ បានសេចក្តីថា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីទី១ជាដើម មិនអាចបញ្ជាទៅកាន់តុលាការឲ្យធ្វើតាមខ្លួនបានឡើយ ។ ទោះបីប្រធានាធិបតីឬប្រមុខរដ្ឋ ក៏ពុំអាចធ្វើដូច្នោះបានដែរ ផ្ទុយទៅវិញ បើរដ្ឋមន្ត្រីណាធ្វើខុសច្បាប់របស់រដ្ឋ តុលាការមានអំណាចជំនុំជំរះកាត់ទោសរដ្ឋមន្ត្រីនោះ ដូចប្រជាពលរដ្ឋទូទៅដែរ គឺមនុស្សគ្រប់ឋានៈ ទាំងប្រជាពលរដ្ឋ ទាំងអ្នករាជការ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់រដ្ឋដូចគ្នា ។ បើតុលាការមិនឯករាជ្យស្ថិតនៅក្រោមអំណាចរដ្ឋាភិបាលនោះ តុលាការពុំអាចកាត់សេចក្តី គឺកាត់ទោសសមាជិករដ្ឋាភិបាលដែលប្រព្រឹត្តខុសបានឡើយ ។ អគតិធម៌ទាំង៤នេះ ជាធម៌ដែលអ្នកធំអ្នកមានអំណាចត្រូវលះបង់ ហើយអនុវត្តតាមគតិយុត្តិធម៌ ជាពិសេសចៅក្រមកាត់សេចក្តី ។ ប្រទេសណាដែលមានចៅក្រមកាត់សេចក្តីពុំលំអៀងដោយអគតិធម៌ទាំង៤នេះ ប្រទេសនោះមានដំណើរឆ្ពោះទៅរកនីតិរដ្ឋហើយ ។ អ្នករំលោភច្បាប់អាចថយចុះ ដោយសារចៅក្រមកាត់សេចក្តីត្រឹមត្រូវ ប្រកបដោយធម៌ ពុំលំអៀង ហើយផ្តន្ទាទោសតាមកំហុសចំពោះអ្នកដែលរំលោភច្បាប់ ។

ចំពោះតុលាការពុំមានយុត្តិធម៌នេះ គេកំពុងភ្ញាក់ផ្អើលនិងស្រឡាំងកាំង ក្នុងករណីលោកឈូក-បណ្ឌិត អតីតអភិបាលក្រុងបាវិត ខេត្តស្វាយរៀង ដែលបានបាញ់កម្មការិនី៣នាក់ ឲ្យត្រូវរបួសធ្ងន់ កាលពីថ្ងៃទី២០ កុម្ភៈ ២០១២ ។ ឥឡូវនេះ តុលាការសាលាដំបូងខេត្តស្វាយរៀង បានដកពាក្យចោទនេះ ដែលកាលពីដំបូងបានចោទលោកឈូក-បណ្ឌិតនេះថា ជាអ្នកបាញ់ដោយអចេតនា ។

តាមសាក្សីនៅកន្លែងកើតហេតុបញ្ជាក់ថា លោកឈូក-បណ្ឌិតជាជនដៃដល់ ក្នុងការបាញ់កម្មការិនីឲ្យរងរបួស ។ ស្របគ្នានេះដែរ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ លោកស-ខេង បញ្ជាក់ថា លោកឈូក-បណ្ឌិតគឺជាមនុស្សតែម្នាក់គត់ ដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងនេះ ។ ចៅក្រមស៊ើបអង្កេតព្រះរាជអាជ្ញាសាលាដំបូងខេត្តស្វាយរៀងបញ្ជាក់ថា លោកសយ-ចន្ថា ជានាយលនគរបាលព្រហ្មទណ្ឌក្រុងបាវិត ជាមនុស្សតែម្នាក់គត់ ដែលស្ថិតក្នុងការសង្ស័យ និងស្ថិតនៅក្រោមការស៊ើបអង្កេតរបស់តុលាការ ។

បន្ទាប់ពីបានទទួលដំណឹងនេះភ្លាម កាលពីថ្ងៃទី១៩ ធ្នូ ២០១២ កម្មការិនី៣នាក់មានការខកចិត្ត និងដាក់ពាក្យបណ្តឹងទៅសាលាឧទ្ធរណ៍ ។ តាមពត៌មាននេះសឲ្យឃើញថា អ្នកតូចតាចគ្មានអំណាចគ្មានបុណ្យស័ក្តិ ពុំអាចក្តីឈ្នះអ្នកមានអំណាចបុណ្យស័ក្តិឡើយ ។

គួរឲ្យអស់សំណើច លោកឈូក-បណ្ឌិតបានបាញ់កម្មការិនីយ៉ាងសាហាវដូចបាញ់សត្វ ព្រះរាជអាជ្ញាសាលាដំបូងចោទថា បាញ់ដោយអចេតនា ។ តើពាក្យចោទថា បាញ់ដោយពុំមានចេតនានេះមានន័យដូចម្តេច ? ។ តាមព្រះពុទ្ធសាសនា បានបង្ហាញថា មនុស្សមុននឹងប្រព្រឹត្តធ្វើអំពើហិង្សាណាមួយ តែងមានចិត្តគិតទុកជាមុន បាលីថាវធកចិត្តំ គឺចិត្តគិតទុកជាមុនប្រកបដោយចេតនា ។ ប៉ុន្តែក្រោយមក បែរជាទម្លាក់ការចោទប្រកាន់នោះទៅវិញ ។ ដូច្នេះ ទោះបីកម្មការិនីប្តឹងទៅសាលាឧទ្ធរណ៍ក្តី ប្តឹងទៅក្រុមប្រឹក្សាអង្គចៅក្រមក្តី ក៏នាងទាំងបីនាក់ពុំអាចទទួលយុត្តិធម៌ឡើយ បើមន្ត្រីទាំងនោះពុំមានគតិធម៌និងពុំមានឯករាជ្យ ។

ក្រៅពីលោកឈូក-បណ្ឌិត មានករណីជាច្រើនទៀតដែលបញ្ជាក់ថា តុលាការមានការលំអៀងពុំមានយុត្តិធម៌ ដូចជាករណី

ភ្នាក់ងារសន្តិសុខចំការកៅស៊ូខេត្តក្រចេះ របស់ឧកញ៉ាមារឌី បានបាញ់រះកម្មករត្រូវរបួសជាច្រើននាក់ ដែលគេមើលឃើញរូបភាពបាញ់យ៉ាងជាក់ស្ដែង តែរហូតមកទល់ពេលនេះ គេពុំទាន់បានទទួលពត៌មានថា ឧក្រិដ្ឋជនត្រូវតុលាការកាត់ឲ្យជាប់ទោសបែបណានៅឡើយទេ ។

លោកឈុត-វុទ្ធី ប្រធានអង្គការការពារបរិដ្ឋាននិងធនធានធម្មជាតិដ៏ល្បីឈ្មោះ បានត្រូវឧក្រិដ្ឋជនបាញ់សម្លាប់ ។ តុលាការពុំបានស្រាវជ្រាវឲ្យល្អិតល្អន់ដោយសុឆន្ទៈ ដើម្បីរកយុត្តិធម៌ជូនអ្នករងគ្រោះឡើយ ។ ក្រោយមក បែរជាបញ្ឈប់ការស្រាវជ្រាវស៊ើបអង្កេតតទៅទៀត ដោយបញ្ជាក់ថា លោកឈុត-វុទ្ធិស្លាប់ទៅហើយ មិនបាច់ស៊ើបអង្កេតទៀតទេ ។

គេនៅចាំបានថា កញ្ញាបញ្ញាពេជ្រ, កញ្ញាទូច-ស្រីនិច ដែលជាតារាចំរៀង ត្រូវឧក្រិដ្ឋជនលួចបាញ់ ក៏តុលាការមិនចាប់យកមកកាត់ទោសឡើយ ព្រោះអំពើទាំងនេះកើតចេញមកអំពីអ្នកមានអំណាចបុណ្យស័ក្តិ ។ អ្នកស្រីពិសិដ្ឋ-ពិលិកាជាគ្រូបង្រៀនខាងសិល្បៈដ៏ល្បីឈ្មោះ បានត្រូវឧក្រិដ្ឋជនលួចបាញ់សម្លាប់ ក៏តុលាការព្រងើយកន្តើយមិនស៊ើបអង្កេត ព្រោះអំពើនេះពាក់ព័ន្ធទៅអ្នកមានអំណាចជាន់ខ្ពស់ ។

លោកជា-វិជ្ជា អតីតប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកការពារកម្មករដ៏ល្បីឈ្មោះ បានត្រូវគេលួចបាញ់សម្លាប់ តុលាការពុំបានចាប់ក្រិដ្ឋជនពិតមកកាត់ទោសឡើយ ។

អ្នកស្រីយោម-បុប្ផា និងអ្នកស្រីទឹម-សាក់ម៉ូនី នៅបឹងកក់និងបុរីកីឡា បានត្រូវតុលាការចេញបញ្ជាឲ្យជាប់ឃុំនៅក្នុងពន្ធនាគារ ដោយសកម្មភាព គ្រាន់តែការពារទ្រព្យសម្បត្តិនិងដីធ្លីរបស់ខ្លួន ។

លោកម៉ម-សូណង់ដូបានត្រូវតុលាការកាត់ទោសឲ្យជាប់ក្នុងពន្ធនាគារជាច្រើនឆ្នាំ ដោយចោទថា បានបង្កើតតំបន់អបគមន៍ បំបែករដ្ឋ ក្នុងស្រុកស្នួល ខេត្តក្រចេះ រហូតអាជ្ញាធរបាញ់សម្លាប់ក្មេងស្រីម្នាក់អាយុ១៤ឆ្នាំស្លាប់ផង ។

លោកសូរិយា-ស៊ូប៊ែឌី បេសកកម្មពិសេសរបស់អង្គការសហប្រជាជាតិ មានការព្រួយបារម្ភអំពីវប្បធម៌និទ្ទណ្ឌភាព និងស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា ។៚

*                 *

*